# ជតាជីវិតអ្នកកើត ឆ្នាំជូត

អ្នកកើតឆ្នាំជូត ពង្សទេវតាប្រុស នាមជាសត្វកណ្តុរ ធាតុទឹក ទន្សាកំណើតនៅថ្ងៃអាទិត្យ មួលព្រលឹងនៅដើមដូង និងដើមចេក កាល ( គួរដាំដើមចេក ឬដើមដូង នៅក្រោយផ្ទះ ដើម្បីសិរីមង្គល) ។

អ្នកកើតឆ្នាំជូត ជាមនុស្សឆ្លាតវៃ មានគំនិតច្នៃប្រឌិត និងចេះសំរបខ្លួនគ្រប់ស្ថានការណ៍។ ជាមនុស្សមានសុទិដ្ឋិនិយម ទន់ភ្លន់ មានភាពស្និទ្ធស្នាល ចុះសម្រុលជាមួយមិត្តភក្តិ តែមាននិស្ស័យចូលចិត្តលេងសើចបន្តិច ជួនកាលគ្រាន់តែនិយាយ ឬសម្តែងកាយវិការ ក៏អាចធ្វើអោយអ្នកជិតខាងសប្បាយរីករាយបានទៅហើយ ។

អ្នកកើតឆ្នាំជូតជាមនុស្សពូកែវិភាគហេតុការណ៍ទុកជាមុន បន្តែគុណវិបត្តិដ៏ធំបំផុតរបស់អ្នកកើតឆ្នាំជូត គឺមិនអាចធ្វើជាមេដឹកនាំ មិនខុសពីសត្វកណ្តុរ ជាសត្វខ្លាច និងទន់ខ្សោយបំផុត ក្នុងចំណោមឆ្នាំទាំង ១២ ។

អាជីពដែលសមស្របសម្រាប់អ្នកកើតឆ្នាំជូត គឺជាអ្នកជំនាញការរ អ្នកនិពន្ធ តន្ត្រីករ សិល្បករ អ្នកវិភាគ គ្រូពេទ្យ អ្នកច្នៃប្រឌិត ។ល។ តែចំពោះស្ត្រីឆ្នាំជូត អាជីពជាអ្នកសំម្តែង អ្នកចម្រៀង បើហាងលក់ចំណីអារហារ ឬភោជនីយាដ្ឋាន ហាងកាហ្វេ។ល។ មានលក្ខណៈប្រសើរជាបុគ្គលិកក្រុមហ៊ុន។ ប៉ុន្តែទោះយ៉ាងណា ជតារាសី អ្នកកើតឆ្នាំជូត ពុំដល់ថ្នាក់លំបាកតោកយ៉ាកទេ បើទោះជាមានពេលខ្លះ រាសីជីវិត អាចធ្លាក់ចុះទាមួយរយៈក៏ដោយ ក៏ភាគច្រើនអ្នកកើតឆ្នាំនេះ មានជីវភាពមធ្យម ។

ចំពោះស្នេហា អ្នកកើតឆ្នាំជូត មិនថាបុរស ឬស្ត្រី គឺជាមនុស្សមានភាពល្អិតល្អន់ យល់ច្បាស់ពីអារម្មណ៍អ្នកដទៃ បុរសភាគច្រើនធ្វើការខាងក្រៅផ្ទះ និងស្ត្រីជាមេផ្ទះដ៏ល្អ ចេះរៀបចំផ្ទះសម្បែងបានល្អ។ ក្រៅពីននេះ ស្ត្រីឆ្នាំជូត ជាមនុស្សមានភាពរឹងមាំ បែជាអ្នកកាទូត ដែលអាចបែងចែកជាពីរប្រភេទ គឺប្រភេទទី១ គឺជាស្ត្រីពូកែ អាចធ្វើការងារទាំងក្នុង និងក្រៅផ្ទះបានដំណាលគ្នា និងប្រភេទទី២ គឺជាស្ត្រីស្រលាញ់ជីវភាព អាចធ្វើការជាច្រើនយ៉ាងបានដំណាលគ្នា។ ស្ត្រីកើតឆ្នាំជូត គួរជ្រើសរើសបុរសកើតឆ្នាំឆ្លូវ ច និងកុរជាគូ។ ឯបុរសឆ្នាំជូត គួរជ្រើសរើសស្ត្រីកើតឆ្នាំរោង វក និងចរ ជាគូ។ ប៉ុន្តែស្ត្រីកើតឆ្នាំជូត មិនអាចជ្រើសរើសបុរសកើតឆ្នាំរោង និងម្សាញ់បានទេ បើរាប់ជាមិត្តប្រសើរជាង។ ក្រមុំឆ្នាំជូត ជាមួយកំលោះឆ្នាំមមី បើទោះជាសម្តង្សត្រូវគ្នា ក៏មិនជាគូនឹងគ្នាដែរ ។ បុរស-ស្ត្រី កើតឆ្នាំជូតដូចគ្នា មិនអាចជាគូនឹងគ្នាបានទេ ( ឆុង) ។

## របៀបទទួលទេវតា

តាមទំនៀមពីបុរាណរៀងរហូតមកមាន រានទទួលទេវតាមួយ សំរាប់តាំងគ្រឿងពលិការផ្សេងៗ ត្រូវរៀបក្រាលសំពត់ពណ៌ស ហើយរៀបបាយសី ៩ ថ្នាក់មួយគូ , បាយសី ៧ថ្នាក់ មួយគូ , បាយសី ៥ ថ្នាក់មួយគូ , បាយសី ៣ ថ្នាក់មួយ បាយសីប៉ាកឆាមមួយគូ, ស្លាធមិមួយគូ , ទឹកអប់មួយគូ , ទៀន ៥ ធូប ៥ , លាច ៥ ,ផ្កាដាក់លើជើងពាន ១ គូ , ចេកនួន ចេកណាំវ៉ា មួយគូ , ផ្លែឈើ ១១ មុខរៀបដាក់ជើងពាន ជាគូៗ , ដូងខ្ចៅ ១ គូ , នៅក្នុងឆ្នាំ ថ្មីនេះ គួដាក់ផ្លែ ល្ហា សំរាប់ថ្វាយទេវតាផង។

ទេវតាចុះនៅម៉ោង ១៨ ម៉ ២៤ នាទី ល្ងាច ថ្ងៃអាទិត្យ ។